# សេចក្តីជូនដំណឹង

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍មានកិត្តិយសសូមប្រកាសជូនដំណឹងជាសាធារណៈដល់បេក្ខជន-បេក្ខនារី នៅឆ្នាំ២០០៨ ក្រសួងត្រូវការ ជ្រើសរើស ក្របខណ្ឌ មន្ត្រីរាជការថ្មីចំនួន ១០រូបឱ្យចូលបម្រើការងារនៅទីស្តីការក្រសួង និងតាមមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្ត-ក្រុង។ បើបេក្ខជន-បេក្ខនារី មានបំណង ចូលរួមក្នុងការប្រឡងប្រជែង នេះអាចសូមចុះឈ្មោះប្រឡងប្រជែងបាននៅក្រសួងប្រៃសណីណ៍ និងទូរគមនាគមន៍ ( ការិយាល័យបុគ្គលិក ) ។

**១. លក្ខខណ្ឌជ្រើសរើស:** បេក្ខជនទាំងពីរភេទត្រូវបំពេញល័ក្ខខណ្ឌ និងបែបបទដូចខាងក្រោមនេះ

- មានសញ្ញាប័ត្រកំរិតបរិញ្ញាប័ត្រឡើងទៅហើយមានអាយុមិនលើស ៣០ឆ្នាំ គិតរហូតដល់ថ្ងៃប្រឡង។
- មានសុខភាពល្អ
- សាមីខ្លួនប្រឡងត្រូវមកសូមចុះឈ្មោះដាក់ពាក្យប្រឡងដោយផ្ទាល់ខ្លួនដាច់ខាត។
- មិនអនុញ្ញាតឱ្យបេក្ខជន-បេក្ខនារី ជាមន្ត្រីរាជការមានក្របខ័ណ្ឌនៅតាមមន្ទីរក្រសួងស្ថាប័នរួចហើយ មកសូមចុះឈ្មោះប្រឡងឡើយ។

បេក្ខជន-បេក្ខនារីត្រូវបំពេញបែបបទប្រឡងនិងដាក់ពាក្យដោយផ្ទាល់ខ្លួនព្រមទាំងនាំមកជាមួយនូវ សញ្ញាប័ត្រ ( ច្បាប់ដើម ) ហើយឯកសារពាក់ពន្ធ័នានាត្រូវផ្តិតមេដៃនិងចុះហត្ថលេខានៅចំពោះមុខមន្ត្រីទទួលពាក្យ។

**២. កំរិតមុខជំនាញជ្រើសរើស និងទីកន្លែងបម្រើការងារ :**

**ក. កំរិត និងមុខជំនាញ**

- គ្រប់មុខជំនាញ ចាប់ពីកំរិតបរិញ្ញាប័ត្រឡើងទៅ ( **លើកលែងតែជំនាញ កសិកម្ម និងសុខាភិបាល** )

**ខ. ទីស្តីការក្រសួង និង មន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ ខេត្ត-ក្រុង**

**៣. សំណុំលិខិតសម្រាប់បេក្ខជន-បេក្ខនារីដាក់ពាក្យប្រឡង:**

- ពាក្យសូមចុះឈ្មោះប្រឡងមានបិទតែមប្រៃសណីយ៍ចំនួន.................................................០១ច្បាប់
- សេចក្តីចម្លងសញ្ញាប័ត្រដោយមានបញ្ជាក់ទទួលស្គាល់ជាផ្លូវការចំនួន...................................០១ច្បាប់
- ជីវប្រវត្តិសង្ខេបមានបិទរូបថត ៤ x ៦ សរសេរដោយផ្ទាល់ដៃចំនួន....................................០១ច្បាប់
- កិច្ចសន្យាបម្រើការងារ( រយៈពេល០៥ឆ្នាំយ៉ាងតិចទើបអាចផ្លាស់ប្តូរឬលាឈប់) ..................០១ច្បាប់
- សលាកប័ត្រ ឯកត្តជនមានបិទរូបថត ៤ x ៦ ( ថតចំពីមុខ)ចំនួន.......................................០១ច្បាប់
- បង្កាន់ដៃបង់ប្រាក់សូមសិទ្ធិប្រឡងមានបិទរូបថត ៤ x ៦ ( ថតចំពីមុខ)ចំនួន.........................០១ច្បាប់

- សេចក្តីចម្លងសំបុត្រកំណើតចំនួន.......................................................................................០១ច្បាប់
- សេចក្តីចម្លងសៀវភៅគ្រួសារឬលិខិតបញ្ជាក់ទីលំនៅឬសៀវភៅស្នាក់នៅចំនួន.....................០១ច្បាប់
- លិខិតថ្កោលទោស ( ក្រោយពេលប្រឡងជាប់ជាស្ថាពរ ) ចំនួន ...........................................០១ច្បាប់
- លិខិតពិនិត្យកាយសម្បទា ( ក្រោយពេលប្រឡងជាប់ជាស្ថាពរ ) ចំនួន .................................០១ច្បាប់

**៤. ទីកន្លែងទទួលពាក្យ និងកាលបរិច្ឆេទទទួលពាក្យ**

**ក.** -ទីកន្លែងទំនាក់ទំនងនិងដាក់ពាក្យប្រឡងនៅនាយកដ្ឋានបុគ្គលិកនិងបណ្តុះបណ្តាលអគារបណ្តោយថ្ងៃជាន់ទី១ ជាប់នឹងផ្លូវលេខ១០២ ក្នុងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ក្នុងសង្កាត់វត្តភ្នំខ័ណ្ឌដូនពេញ ។

**ខ.** -ផ្តល់ព័ត៌មាននិងទទួលពាក្យនៅរៀងរាល់ថ្ងៃធ្វើការចាប់ពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ។

☛ ព្រឹក ចាប់ពីម៉ោង ០៨:០០ ដល់ម៉ោង ១១:០០ ព្រឹក

☛ ល្ងាច ចាប់ពីម៉ោង ១៥:០០ ដល់ម៉ោង ១៧:០០ ល្ងាច

**គ.** -កាលបរិច្ឆេទទទួលពាក្យចាប់ពីថ្ងៃជូនដំណឹងនេះតទៅរហូតដល់ថ្ងៃសុក្រទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៨ វេលាម៉ោង ១៧:០០ ជាកាលបរិច្ឆេទឈប់ទទួលពាក្យ ។

**៥. វិញ្ញាសា និង ថេរវេលាប្រឡង**

| | | |
|---|---|---|
| - វិញ្ញាសា សរសេរ | វប្បធម៌ទូទៅ : | ម៉ោង ០៧:១៥ ដល់ម៉ោង ០៨:៤៥ |
| - វិញ្ញាសា សរសេរ | គណិតវិទ្យា : | ម៉ោង ០៩:០០ ដល់ម៉ោង ១០:៣០ |
| - វិញ្ញាសា សរសេរ | ភាសាបរទេស : | ជ្រើសរើស ( អង់គ្លេស ឬ បារាំង ) ចាប់ពីម៉ោង ១០:៤៥ ដល់ម៉ោង ១១:៤៥ |

**៦. មណ្ឌលប្រឡង** ( ជូនដំណឹងនៅពេលក្រោយ )

**៧. កាលបរិច្ឆេទប្រឡង** ព្រឹកថ្ងៃអាទិត្យទី ០៥ ខែតុលា ឆ្នាំ២០០៨

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍សង្ឃឹមថាសាធារណៈជនគ្រប់មជ្ឈដ្ឋាននិងបេក្ខជន-បេក្ខនារី និងជួយសហការគាំទ្រវិធានការនេះដើម្បីដំណើរការប្រឡងជ្រើសរើសមន្ត្រីរាជការនេះប្រកបដោយសុក្រឹត្យនិងយុត្តិធម៌ ។